# សិលាចារឹកប្រាសាទតាមាន់ធំ K.១១៨៦

## ១- សេចក្តីទូទៅ

ប្រាសាទតាមាន់ធំ មានឈ្មោះបុរាណថា «សិវបាទបស្ចិម» គឺជាប្រាសាទបុរាណខ្មែរមួយលើជួរភ្នំដងរែក ស្ថិតនៅក្នុងភូមិតាមាន់ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ[១] ដែលមានរយៈបណ្តោយ ៣១៣០៨៣ និងរយៈទទឹង ១៥៨៧០៨៥[២]។ ប្រាសាទនេះជាស្ថាបត្យកម្មនាស.វ.ទី១១ ក្នុងរាជ្យព្រះបាទស្រីសូរ្យវរ្ម័ទេវទី១ សាងនៅលើចម្រាក់ភ្នំ បែរមុខទៅទិសខាងត្បូង សម្របតាមទីតាំងភូមិសាស្ត្រជាក់ស្តែង។ ប្រាសាទនេះពុំមានប្រតិមាអ្វីដែលគួរឲ្យកត់សម្គាល់នោះទេ គឺមានតែលិង្គធម្មជាតិ ឬស្វយម្ភូលិង្គដែលភ្ជាប់ទៅក្រោបរិវេណប្រាសាទតាមចង្អូរថ្ម ដែលគេរៀបចំសម្រាប់ឲ្យទឹក មន្តស្រោចស្រពក្នុងពិធីលើលិង្គនោះហូរទៅក្រៅ ដើម្បីសាសនិកនានាត្រងយកទៅប្រើក្នុងជំនឿ[៣]។ នៅប្រាសាទនេះរកឃើញសិលាចារឹកសរុបចំនួន១៤ផ្ទាំង[៤] ដែលមានតាំងពីស.វ.ទី៧ រហូតមក។ នៅទីនេះ នឹងលើកយកសិលាចារឹកមួយផ្ទាំង ចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹក K.១១៨៦ មានចុះកាលបរិច្ឆេទនៅក្នុងឆ្នាំ១០១៣ ក្នុងរាជ្យព្រះបាទស្រីសូរ្យវរ្ម័ទេវទី១។

អត្ថបទសិលាចារឹកនេះ ចារជាភាសាខ្មែរបុរាណ មានអត្ថបទចារឹកសង្ខាង នៅលើផ្ទាំងថ្មរាងជាសន្ទឹកសីមា។ សព្វថ្ងៃសិលាចារឹកនេះ រក្សាទុកនៅសារមន្ទីរខេត្តសុរិន្ទ ប្រទេសថៃ។ អត្ថបទផ្ទាំងក មានអត្ថបទសរុបចំនួន១៩បន្ទាត់ និងផ្ទាំងខ មានអត្ថបទសរុបចំនួន១៨បន្ទាត់។ ចំពោះខ្លឹមសារនៃអត្ថបទនេះ គឺនៅមហាសករាជឆ្នាំ៩៣៥ (គ.ស.១០១៣) ព្រះបាទស្រីសូរ្យវរ្ម័ទេវទី១ ត្រាស់បង្គាប់ឲ្យកំស្តែងអញស្រីរាជេន្ទ្រវរ្ម័ទូលបន្ទូលទ្រង់ត្រាស់បន្តដល់ខ្ញាញស្តុកក្មោះឈ្មោះលោញសិខាសិវ ដើម្បីស្ថាបនាព្រះរាជសាសន៍(ចារសិលាចារឹកតម្កល់ទុក)នៅប្រាសាទសិវបាទបស្ចិម គឺប្រាសាទតាមាន់ធំនេះ។ ព្រះអង្គសព្វព្រះរាជហឫទ័យ

---

[១] យាន យ៉ា, `ប្រាសាទតាមាន់ធំ' (បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២០១៤), ៨.

[២] អាំង ជូលាន, `ប្រាសាទតាមាន់ធំ', accessed 19 December 2025, https://www.yosothor.org/publications/khmer-renaissance/chapter-four/prasat-ta-morn-thom.html.

[៣] អាំង, `ប្រាសាទតាមាន់ធំ'.

[៤] យាន, `ប្រាសាទតាមាន់ធំ', ១៣៨.

*នឹងអ្នកទាំងឡាយមានគុរុជនទាំងឡាយ ជននីទាំងឡាយ ម្រតាញស្រីទ្រីបេទ្រាវាល្វក ព្រមទាំងម្រតាញខ្ញុំញដទៃទៀត ដែលបានកសាងបុណ្យ និងលើកថ្វាយបុណ្យនេះជាព្រះរាជធម៌នៃព្រះអង្គ។ អ្នកទទួលបន្ទុកចារសិលាចារឹក គឺម្រតាញខ្ញុំញស្រីក្សិតិន្ទ្រាបកល្ប។ ព្រះបាទស្រីសូរ្យវម៌្មទេវទី១ ក៏ត្រាស់បង្គាប់ឲ្យថ្វាយតង្វាយមានស្នែងដិះ គ្រឿងបរិភោគ សម្ភារៈផ្សេងៗ ខ្ញុំបម្រើន និងរឿងរណ្តាប់ដទៃទៀតថ្វាយប្រាសាទ។*

*សេចក្តីបន្ត គឺនិយាយអំពីការដោះដីព្រៃស្តុកភ្ទោះ ថ្វាយប្រាសាទតាមាន់ធំនេះ។ សាច់រឿងលើកតាំងពីរាជព្រះបាទស្រីជ័យវម៌្មទេវទី៥ មានមន្ត្រី៤នាក់ និងអ្នក៦នាក់ទៀត ព្រមទាំងក្រុមគ្រួសារ និងក្រុមខ្ញុំ រួមគ្នាដោះដីព្រៃស្តុកភ្ទោះពីលោកម្ចាស់ប្រាសាទ។ សេចក្តីបន្តមានរៀបរាប់អំពីព្រំប្រទល់ដី ព្រមទាំងទ្រព្យសម្រាប់ដោះដីនោះផង។ ដោះដីរួច ក៏ចាត់ចែងជាភូមិស្រុក ទុករណ្តាប់បូជា សង់ក្រលាពំ មានអ្នករាំ អ្នកច្រៀង អ្នកលេងភ្លេងសម្រាប់ខាងខែខ្នើតផង។ បន្ទាប់មកជាបញ្ជីកត់ត្រាឈ្មោះខ្ញុំបម្រើស្រីប្រុស ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយដែលព្រះករុណាទ្រង់ថ្វាយចំពោះប្រាសាទ។ លោញសិខាសិវ បានប្រើឲ្យកូនចៅជំនាន់ក្រោយថែរក្សាខ្ញុំបម្រើនិងទ្រព្យសម្បត្តិទាំងឡាយនោះ។ ចុងក្រោយជាបណ្តាសាដល់អ្នកដែលលុបបំបាត់បុណ្យដែលបានសាងទាំងអស់នេះ ឲ្យធ្លាក់ក្នុងនរក៣២ជាន់ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន។*

## ២- *អត្ថបទ និង សេចក្តីបកប្រែ*

### ២.១- *អត្ថបទបុរាណជាអក្សរខ្មែរទំនើប*

**ផ្ទាំងក**

១- ៩៣៥ឝក្ក ◦ ចតុជ៌្ឝិរោចខែត្រ ◦ ព្រហស្បតិវារ

២- ទុមាន៑ ព្រះការុណាតបរមបវិត្រ ◦ តតាំស្តេង៑អញ ត្រិភាជ

៣- ទ្រវ្យម្ទិបនិទូលិ ព្រះកាសនតខ្ញុំវលស្តុតវ្ហ៊ាតង្វះហ៊ាលោ

៤- ញុំតិខាតិវបិ ប្រែ ពៅស្ពាបជាប្រែកស្ពអាយ៏តាំម្រែតេង៑ជក

៥- តតិវថានបក៌្សមតតិជម្និគុរុជននែងទុជនជិយនែងទុម្រតា

៦- ញុំត្រិឆ្នូបេជ្ញាវាលិលកតថ្វាយជាព្រះរាជធម្មិតតាំម្រែតេង៑កាំតួនអ

៧- ញត្រីសូរ្យវម្មិនេវយូកចាតន្ទុម្រតាញខ្ញុំត្រិឥតាន

៨- វម្មិនុម្រតាញខ្ញុំត្រិភាជ ទ្រវ្យបក្ថិតន្ទុម្រតាញខ្ញុំត្រិកឝ្មិត្តិ ប្រាប

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

៩- កល្បខ្លោញវលចន៑ហ្វារត្រោស៑◦ ឋិប្រេម្រតាញខ្លោញត្រិក្សិត្តិជ្រោប

១០- កល្បនៅស្ទាបជាប្រកស្តុអាយកំម្រតេង៑ជគា[ត៑]គិវថាន◦ មានវ្រះ

១១- ការុជាតបរមបវិត្រតខ្លោញវលស្តុកវ្រះតជ្ទះលោញគិខាគិវបន្ទូលប្រែ

១២- ជិ[[០ះ]]ស្នេង៑ភោគវុទ្ធិបទិគះវាគិឆាតប្រែអាយាត្ទខ្ញុំនុចំជាមិគបិមានិជា

១៣- អាយាត្ទតនៃយ្តិ◦ តគិរាជវ្រះថានស្តាចនៅបរមវិរលោកគិកាលខ្លោញ

១៤- វលតស្វតិជ្ទះលោញទ្រវ្យាបិនុតេង៑មាទ្ធិវិទុម្រតាញត្រិន្ទូបជ្រាវាល្វិកអាន្ទ

១៥- មោទិបិដោវិក្សមិវ្រៃយស្តុកវ្រះតថានម្វលកំម្រតេង៑ជគាត្តិខ្លោញវលត

១៦- ជ្ទះលោញត្រិជនញ្ញោយខ្លោញវលតជ្ទះលោញហិយលោញវ្រាហ្មលោញត្រេ

១៧- ម្ទលោញចាំ(ម)លោញបិតិទុក្កុលេអ្នក្តអថាលនេះហាទុវាគ្តិខ្តោដោង៑សំមយូក

១៨- ដ្ឋោវិក្សមិត្រៃរោះហានេះហាតគិកាលជ្នោះគិតរាបក្សមិតិដោវិតោយប្វៀ

១៩- តរាបិត្រវាង៑ស្រវានិតោយិទក្សិនតរាបិអថិតេកជាវ្រះបំន្វសិថ្ងេតថាះ

## ផ្ទាំង១

១- តោយបក្តិមតរាបិស្តុកតោយឧត្តរតរាបិផ្ទុត្រាចបរិហារទ្រាវ្យមនិឱយិត អ្នក្តារោះហា

២- នេះហាបិដោវិក្សមិច្រាកិលិង៑១០មាសលិង៑១វុទ្ធិ២បទិគះ២ទោង៑៨ដេង៑បរា (សិ៧) (នោកិ?) ៨ (ដ្នោសិ)

៣- ៦ដ្នោសិបរតិ៤ចន្សាកិ១០០យោ១០ជ្ទុរ១០០-៤០-៦រដ្ឋោ២០ក្របិ១ជ្រូកិ១ វាវ២ស្នុរាចេះ១០-២នេះតិ

៤- ឱយិចាយិឱយិទ្រាវ្យតអំចាលនេះហាដោវិក្សមិវ្រៃយស្តុកវ្រ[[០ះ]]◦ ចតិស្រុកិ ទុកិចំជាមិលិះ៤

៥- ប្រតិទិនតោយិខ្ទោត្តសង៑ក្រលារាមិទុកិម្នាមិចំយ្យាង៑ជ្នង៑ថ្នោង៑តំល្វមិម្វាយ្យេរ តោយិ

៦- ខ្ទោត្តខ្ញុំមនិជ្វន្តកំម្រតេង៑ជគាតិនៃដ្តោវិតៃកំថាញតៃកន្វេសិតៃកំបិតិតៃ កំប្វុវិតៃ

៧- កំទ្វាតិតៃកនិរេនិ◦ តៃថ្វេតៃបនិហោមិតៃជ្នាមិតៃច្វេសិតៃកំវិតិតៃថ្យុកិតៃត្រា

៨- ម្តតៃបរាង៑តៃកំភតៃកំជ្យាចតៃកនិននិតៃកំបុរតៃកនិអោះតៃតិជិតៃសំ

៩- អបិតៃកន្វង៑តៃអ្កតិតៃត្រានតៃកនិជនិតៃកំស្វុរតៃកំវៃម◦ យោជម្និទាសយោ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១០- កញ្ញុំជយោត្រិយោកក្ដោសិយោអ្នត្តយោថ្វយោកំវលយោខ្មោវ៉យោបិត្តរ
យោគ

១១- ឆ្វយោគនិសានិយោរាំយោព្រាឡ្មាយោកន្ទុបិយោគនិសានិយោកឆ្វានិ
យោជនេត្រ្វ

១២- យោកក្រ្វាមិយោអំបេនិយោគឆ្វបិ៰ ទ្រាវ្យមនិជូន្តកំម្រតេងជគាត់តំម្រ្យ២
គនៈ-ំ

១៣- និ២ត្រយ្វងភ្នក់២ទ្រាក់ជ្យង១មាសលិង១ក្រាបិ៦ជាសិ២វុទិ៤ប[ទិ]គះ៦គនា

១៤- ហា២ស្រោក់២កាជ២ខ្ញុំ៤០-៨នេះខ្ញុំតអចាលនេះហាតិទាព្រះការុជាប្រ

១៥- សានឆុមនិមានឆុមាន្និយនៃយកាល្បជាផ្ងយក្រលាភមិដោះមនិខ្ញុំញ្ញ

១៦- វលតស្វតិថ្ងអាយត្តតក្វនខ្ញុំញ្ញវលតស្វត្តដ្មោ[០ះ]លោញ្ញតិខាតិវន្ទុក្វាផ្ចៅវ

១៧- ដោះហាតិជាខ្ញុំញ្ញវលតស្វតសមាបេខ្ញុំនេះឆុជម្និតរោះហានេះប្រែបវិចាល

១៨- ដោអ្នក្តលបជម្និតរោះហានេះហាជាំម្តុក្វាត្រិគនរកាតរាច្វាព្រ្វានិត្យមាឆ្វយ

## ២.១- អត្ថបទសម្រួលជាភាសាខ្មែរទំនើប

(ក១-៧) មហាសករាជឆ្នាំ៩៣៥ ថ្ងៃទី៤រោច ខែចេត្រ ថ្ងៃព្រហស្បតិ៍ នូវមានព្រះករុណាតបរមបពិត្រ(ត្រាស់)ដល់កំស្តែងអញស្រីរាជេន្ទ្រវម្ម័ (យក)បន្ទូលព្រះរាជសាសន៍(ឲ្យ)ដល់ខ្លោញស្តុកគ្វោះដែលឈ្មោះលោញសិខាសិវ ដើម្បីប្រើឲ្យទៅស្ថាបនាសិលាចារឹកឯគម្តែងជគតសិវបាទបស្ចិម (=ប្រាសាទតាមាន់ធំ) ដែលជាបុណ្យ(ធម៌)គុរុជនដទៃ នូវជនទីដទៃនូវម្រតាញស្រីទ្រឹបេន្ទ្រាវាល្លភ ដែល(លើក)ថ្វាយជាព្រះរាជធម៌ចំពោះព្រះគម្តែងកំដូនអញស្រីសូរ្យវម្ម័ទេវ រួមនឹងម្រតាញខ្លោញស្រីឦសានវម្ម័ និងម្រតាញខ្លោញស្រីរាជេន្ទ្របណ្ឌិត និងម្រតាញខ្លោញស្រីក្សិតិន្ទ្រាបកល្ប ខ្លោញពលចង្វរគ្រួស។ គប្បីប្រើម្រតាញខ្លោញស្រីក្សិតិន្ទ្រាបកល្បទៅស្ថាបនាសិលាចារឹកឯគម្តែងជគតសិវបាទ(បស្ចិម)។

(១០-១៣) មាន(ព្រះបន្ទូល)ព្រះករុណាតបរមបពិត្រ(ត្រាស់)ដល់ខ្លោញពលស្តុកគ្វោះដែលឈ្មោះលោញសិខាសិវបន្ទូលប្រើ(យក)ស្នេងជិះ គ្រឿងបរិភោគ ចូវៅទិ កន្ទោរស្ពោះ ខ្សែក្រវាត់ ឆត្រ ប្រើឲ្យខ្ញុំបម្រើ និងគ្រឿងវណ្ដាប់ (ព្រមទាំង)ឲ្យ(ទ្រព្យ)ដទៃទៀត។

(១៣-១៥) កាលរាជ្យព្រះបាទស្តេចយាងទៅស្ថានបរមវីរលោក (ជ័យវម្ម័ទេវទី៥) គឺកាលខ្លោញពល(ជាអ្នក)សូត្រ(ព្រះធម៌សាស្ត្រ?)ឈ្មោះលោញរុទ្រាវ្យាបិ និងតេងមាទ្ធិវី និង

*ម្រតាញ៑ស្រីន្ទ្រីបេន្ទ្រាវល្ងក អនុមោទនាជាវដីព្រៃស្តុកក្ញោះពីលោកម្ចាស់(=បាទមូល) នាគម្តែងជគត្តុ។*

*(១៥-១៨) ខ្ញោញពលឈ្មោះលោញស្រីធញ្ជ័យ ខ្ញោញពលឈ្មោះលោញហិយ លោញវ្រាហ្ម លោញស្រេស្ឋ លោញចាំ លោញបិត និងក្រុមគ្រួសារអ្នកទាំងអម្បាលនេះ ព្រមទាំងក្រុមខ្ញោផង (ក៏)រួមគ្នាជាវដីព្រៃទាំងអស់នេះក្នុងកាលនោះ។*

*(១៨-២១) (ព្រំប្រទល់)ដីដែលជាវ ទៅបូព៌ជាបត្រពាំងស្រវាន ទៅទក្សិណជាប អាចម៍ដែកនាព្រះបំនួសធ្វើតបៈ ទៅបស្ចិមជាបស្តុក ទៅឧត្តរជាបផ្លូវគ្រាច។*

*(២១-៤) ចាត់បែងទ្រព្យឲ្យដល់អ្នកទាំងអស់នេះ ដើម្បីជាវដី(មាន)ប្រាក់១០តម្លឹង មាស ១តម្លឹង ចូវៅទិ២ កន្តោរស្តោះ២ ដំបង៥ ដើងបរាស៧ (ទូក)៥ (គោ)ឈ្មោល៦ គោប្រណាំងឈ្មោល៤ សម្បៀក១០០ចំនួន១០យៅ គោ(ញី)១៤៦ អង្ករ២០ ក្របី១ ជ្រូក១ ពពែ២ ស្រា១២ពាង(=ចេះ)។ ឲ្យបាយ ឲ្យទ្រព្យទាំងអម្បាលនេះ (ដើម្បី)ជាវដីព្រៃស្តុកក្ញោះ។*

*(៤-៦) ចាត់(បែងជាភូមិ)ស្រុក ទុករណ្តាប់បូជា(អង្ករ)៤លិះ ប្រចាំថ្ងៃខាងខ្នើត ។ សង់ក្រលារាំ ដាក់អ្នករាំ អ្នកច្រៀង អ្នកដេញភ្លេង អ្នកទូង តំលូម(គង់វង់?) ១វេនខាងខ្នើត ។*

*(៦-១២) ខ្ញុំបម្រើដែលថ្វាយគម្តែងជគត ដទៃទៀត(មាន)តៃកំបាញ តៃកន្ទេស តៃកំបិត តៃកំបុរ តៃកំខ្វាត តៃកន្រេន តៃថ្ងៃ តៃបន្ទោម តៃនោម តៃច្មេស តៃកំវិត តៃផ្សុក តៃស្រាស្ត តៃបរោង តៃកំភ តៃកំបា្យច តៃកន្ទន តៃកំបុរ តៃកន្អោះ តៃតិចំ តៃសំអប តៃកន្ទុង តៃអ្គុត តៃស្រាទ តៃកន្ទួន តៃកំសុរ តៃកំពិស។ ឃោជម្ពុទាស ឃោញកញ្ចូ ឃោស្រី ឃោកន្ទោស ឃោអនន្ត ឃោថ្ងៃ ឃោកំវល ឃោខ្មៅ ឃោបិត្តុរ ឃោគន្ធ ឃោកន្សាន ឃោរំ ឃោវ្រាហ្ម ឃោកន្ទេប ឃោកន្សាន ឃោកន្ទាន ឃោជនេន្ទ្រ ឃោកន្ទ្រោម ឃោអំបេន ឃោកន្ទបៗ*

*(១២-១៥) ទ្រព្យដែលថ្វាយដល់គម្តែងជគត(សិវបាទបស្ចិម មាន) ដំរី២ គន--២ ត្រយូងភ្នាក់២ ប្រាក់១ជញ្ជីង មាស១តម្លឹង ក្របី៦ ថាស២ ចូវៅទិ៤ កន្តោរស្តោះ៦ ខ្ចះ២ ស្តោក២ ភាជន៍២ ខ្ញុំបម្រើ៤៨នាក់។ អ្នកបម្រើទាំងអម្បាលនេះ ទទួលបានពីព្រះករុណាប្រទានដែលមាន និងបានពីអ្នកដទៃ។*

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

(១៥-១៧) រណ្ដាប់បូជាជាផលនាក្រលាពំនោះ គឺខ្ញោញវល(ជាអ្នក)សូត្រ(ព្រះធម៌សាស្ត្រ?)បានធ្វើឲ្យទៅកូនខ្ញោញពល(ជាអ្នក)សូត្រ(ព្រះធម៌សាស្ត្រ?) ឈ្មោះលោញសិខាសិវ និងកូនចៅនោះ គឺខ្ញោញពលឲ្យខ្ញុំបម្រើនិងបុណ្យ(=ធម៌)ទាំងនេះ ប្រើឲ្យថែរក្សា។

(១៨) នៅអ្នកដែលលុបបំបាត់បុណ្យទាំងអស់នេះ ដាំ(ត្រាំក្នុង)ទ្វាត្រឹង្សនរកដរាបព្រះចន្ទ្រនិងព្រះអាទិត្យ(នៅ)មានឡើយ។

## ៣- សរុប

សិលាចារឹកប្រាសាទតាមាន់ធំ K.១១៨៦ គឺជាឯកសារដ៏មានតម្លៃសម្រាប់ការសិក្សាអំពីអក្សរសាស្ត្រ និងប្រវត្តិសាស្ត្រខ្មែរ។ អត្ថបទនេះបង្ហាញពីការប្រើប្រាស់ភាសាខ្មែរបុរាណ យន្តការនៃការត្រាស់បង្គាប់ព្រះរាជបញ្ជារបស់ព្រះមហា។ ព្រមជាមួយគ្នានេះសិលាចារឹកនេះក៏បានបង្ហាញពីការប្រតិបត្តិសាសនា ការថ្វាយតង្វាយនានា និងជំនឿនៃការដាក់បណ្ដាសា ដើម្បីបង្ការការខូចខាតរាល់បុណ្យដែលបានកសាង។ ការរៀបរាប់អំពីការថ្វាយទ្រព្យសម្បត្តិ និងការចាត់ចែងអ្នកបម្រើ បង្ហាញពីរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ច និងការចែកចាយធនធានក្នុងសម័យអង្គរ។

បន្ថែមពីនេះ សិលាចារឹកនេះ ក៏បង្ហាញពីអំណាចព្រះមហាក្សត្រ ដែលបានប្រើសាសនា ដើម្បីបង្កើនសិទ្ធិអំណាចនយោបាយ និងឋានៈរបស់ព្រះអង្គ។ ការថ្វាយដី និងទ្រព្យ ទៅប្រាសាទមិនត្រឹមតែជាការបូជាសាសនាទេ ប៉ុន្តែជាវិធីសាស្ត្រដើម្បីបង្កើនស្ថិរភាពនយោបាយ និងសង្គម។ ការកំណត់ព្រំប្រទល់ដី ការរៀបចំរណ្ដាប់បូជា និងបញ្ជីអ្នកបម្រើបង្ហាញពីប្រព័ន្ធច្បាប់ និងសីលធម៌ដែលភ្ជាប់ជាមួយសាសនា។ ដូច្នេះ សិលាចារឹកនេះមិនត្រឹមតែជាឯកសារបុរាណទេ ប៉ុន្តែជាកញ្ចក់បង្ហាញពីវប្បធម៌ សាសនា និងរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចរបស់អង្គរនៅសតវត្សទី១១។

## បញ្ជីឯកសារ

យាន យ៉ា. `ប្រាសាទតាមាន់ធំ'. បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២០១៤.

អាំង ជូលាន. `ប្រាសាទតាមាន់ធំ'. Accessed 19 December 2025. https://www.yosothor.org/publications/khmer-renaissance/chapter-four/prasat-ta-morn-thom.html.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



n. 1684 / K. 1186

សំណៅផ្តិតសិលាចារឹកប្រាសាទតាមាន់ធំ K.១១៨៦ ផ្ទាំងក (ប្រភព៖ EFEO & CISARK)



n. 1685 / K. 1186

សំណៅផ្តិតសិលាចារឹកប្រាសាទតាមាន់ធំ K.១១៨៦ ផ្ទាំងខ (ប្រភព៖ EFEO & CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង